កម្មវិធីកែទម្រង់

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

MINISTRY OF ECONOMY AND FINANCE

សិក្ខាសាលាស្តីពីការបញ្ជ្រាបការយល់ដឹង
អំពីវិធីសាស្ត្រនៃការវិភាគ SWOT
និងការរៀបចំគេហទំព័ររបស់មន្ទីរ
សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

វាគ្មិន | Speaker
សិក្ខាសាលាស្តីពីការបញ្ជ្រាបការយល់ដឹងអំពីវិធីសាស្ត្រនៃការវិភាគ SWOT
និងការរៀបចំគេហទំព័ររបស់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
****
Workshop for Raising Awareness on SWOT Analysis Methodology and Website Preparation Of Provincial Departments of Economy and Finance
បទបង្ហាញ | Presentation
ការវិភាគ SWOT នៃខេត្ត Aichi នៃប្រទេសជប៉ុន
ការវិភាគ SWOT របស់មន្ទីរ សហវ. រាជធានីភ្នំពេញ
ការវិភាគ SWOT របស់មន្ទីរ សហវ. ខេត្តព្រះសីហនុ
ការវិភាគ SWOT របស់មន្ទីរ សហវ. ខេត្តបន្ទាយមានជ័យ
ក្របខណ្ឌនៃការវិភាគ SWOT និងទិដ្ឋភាពប្រៀបធៀប ផ្នែកសង្គម-សេដ្ឋកិច្ចនៅកម្រិត រាជធានី-ខេត្ត
ទស្សនាទាននៃគោលនយោបាយជាតិ ស្តីពី ផលិតភាពសេដ្ឋកិច្ចកម្ពុជា
ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គម ឌីជីថលកម្ពុជា ២០២១-២០៣៥
សេចក្តីព្រាងគេហទំព័រនិងទម្រង់បង្ហាញទិន្នន័យ
អំពី | About
ប្រព្រឹត្តទៅតាមប្រព័ន្ធ Video Conference ដោយមានការចូលរួមពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំង ២៥ រាជធានី-ខេត្ត
ដឹកនាំដោយឯកឧត្តម យ៉េត ទីរីណាល អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ.) និងជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការ នៃ កសហវ. និងជាអគ្គលេខាធិការ នៃ អ.គ.ហ.។
សម្របសម្រួលកិច្ចពិភាក្សាដោយ លោក អ៊ុំ យុទ្ធី ប្រធានផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងត្រួតពិនិត្យនិងវាយតម្លៃ នៃ អ.គ.ហ.
សម្របសម្រួលការរៀបចំសិក្ខាសាលាដោយ ក្រុមការងារផ្នែកថវិកា នៃផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងត្រួតពិនិត្យនិងវាយតម្លៃ នៃ អ.គ.ហ.
គោលបំណង | Purpose
ពិនិត្យ និងពិភាក្សាលើទម្រង់គំរូគេហទំព័រ និងទិន្នន័យដែលត្រូវផ្សព្វផ្សាយលើគេហទំព័ររបស់មន្ទីរ សហវ. ក៏ដូចជាចែករំលែកចំណេះដឹងអំពីវិធីសាស្ត្រ និងឧបករណ៍សម្រាប់ការវិភាគ SWOT ដែលជាមូលដ្ឋានចំណេះដឹងសម្រាប់រៀបចំផែនការសកម្មភាពដើម្បីចូលរួមជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។
អ្នកសម្របសម្រួល
13 កក្កដា 2021
ព្រឹក - Morning
08:15 - 12:30
ល្ងាច - Afternoon
01:30 - 05:30
ឯកសារ
រៀបចំដោយ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
(+855) 85 777 924
www.pfm.gov.kh
gsc@pfm.gov.kh
www.facebook.com/gscpfm

មាតិកា

របៀបវារៈ

ការវិភាគ SWOT នៃខេត្ត Aichi នៃប្រទេសជប៉ុន ១

ការវិភាគ SWOT របស់មន្ទីរ សហវ. រាជធានីភ្នំពេញ ២

ការវិភាគ SWOT របស់មន្ទីរ សហវ. ខេត្តព្រះសីហនុ ៣

ការវិភាគ SWOT របស់មន្ទីរ សហវ. ខេត្តបន្ទាយមានជ័យ ៤

ក្របខណ្ឌនៃការវិភាគ SWOT និងទិដ្ឋភាពប្រៀបធៀបផ្នែកសង្គម-សេដ្ឋកិច្ចនៅកម្រិត រាជធានី-ខេត្ត ៥

ទស្សនាទាននៃគោលនយោបាយជាតិ ស្តីពីផលិតភាពសេដ្ឋកិច្ចកម្ពុជា ៦

ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឱជីថលកម្ពុជា ២០២១-២០៣៥ ៧

សេចក្តីព្រាងគេហទំព័រនិងទម្រង់បង្ហាញទិន្នន័យ ៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
លេខ:...២៥៣...សហ១/អគហ...

ថ្ងៃចន្ទ ០៥រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១

ជម្រាបជូន

លោក លោកស្រី ប្រធានក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
នៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

កម្មវត្ថុ: សំណើអញ្ជើញចូលរួមសិក្ខាសាលាស្តីពីការបញ្ជ្រាបការយល់ដឹងអំពីវិធីសាស្រ្តនៃការវិភាគ **SWOT** និងការរៀបចំគេហទំព័ររបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន លោក លោកស្រី ជ្រាបថា តាមការពិភាក្សា និងឯកភាពក្នុងសិក្ខាសាលាបញ្ជ្រាបការយល់ដឹងអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងរដ្ឋបាលតាមប្រព័ន្ធអេឡិចត្រូនិក ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ **(អ.គ.ហ)** បានសិក្សាតម្រូវការបច្ចេកទេស និងបានរៀបចំទម្រង់គំរូគេហទំព័ររបស់មន្ទីរ សហវ. រាជធានី-ខេត្ត។ ម្យ៉ាងទៀត **អ.គ.ហ.** ក៏បានស្រាវជ្រាវពីវិធីសាស្រ្តដែលជាឧត្តមានុវត្តន៍អន្តរជាតិសម្រាប់ធ្វើការវិភាគភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង។

ក្នុងន័យនេះ **អ.គ.ហ.** នឹងរៀបចំសិក្ខាសាលាស្តីពីការបញ្ជ្រាបការយល់ដឹងអំពីវិធីសាស្រ្តនៃការវិភាគ SWOT និងការរៀបចំគេហទំព័ររបស់មន្ទីរ សហវ. ដើម្បីពិនិត្យនិងពិភាក្សាលើទម្រង់គំរូគេហទំព័រ និងទិន្នន័យដែលត្រូវផ្សព្វផ្សាយលើគេហទំព័រ ក៏ដូចជាចែករំលែកចំណេះដឹងពីវិធីសាស្រ្ត និងឧបករណ៍ សម្រាប់ការវិភាគ SWOT ដើម្បីជាមូលដ្ឋានក្នុងការគិតគូររៀបចំផែនការសកម្មភាពសម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។ សិក្ខាសាលានេះនឹងរៀបចំ ***នៅថ្ងៃទី...១៣... ខែ...កក្កដា... ឆ្នាំ២០២១ វេលាម៉ោង...០៨:៣០ ព្រឹក... តាមរយៈប្រព័ន្ធ Video Conference*** ដូចមានរបៀបវារៈជូនភ្ជាប់មកជាមួយនេះ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី ចូលរួមសិក្ខាសាលាខាងលើ តាមការគួរ។

សូម លោក លោកស្រី ទទួលនូវគោរពរាប់អានពីខ្ញុំ។

រដ្ឋលេខាធិការ
និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

រស់ សីលវ៉ា

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ: ៨៥៥-២៣-៤៣០ ៧៩១ ទូរសារ: ៨៥៥-២៣-៤៣០ ៧៤៥
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA Phone : 855-23-430 791 Fax: 855-23-430 745

សេចក្ដីព្រាងរបៀបវារៈ

សិក្ខាសាលាស្ដីពីការបញ្ជ្រាបការយល់ដឹងអំពីវិធីសាស្ត្រនៃការវិភាគ SWOT និងការរៀបចំគេហទំព័ររបស់មន្ទីរ សហវ.

តាមប្រព័ន្ធ Video Conference, ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១

ម៉ោង	របៀបវារៈ	អ្នកទទួលខុសត្រូវ	លទ្ធផលរំពឹងទុក
	កម្មវិធីពេលព្រឹក		
០៨:១៥-០៨:៣០	**ចុះឈ្មោះ**		
០៨:៣០-០៨:៤៥ (១៥នាទី)	**មតិស្វាគមន៍ និងបើកអង្គសិក្ខាសាលា**	ឯកឧត្ដម **យ៉េត វីណែល** អនុរដ្ឋលេខាធិការ កសហវ. និងជាអគ្គលេខាធិការរង អ.គ.ហ.	
០៨:៤៥-០៩:៣០ (៤៥នាទី)	**ការវិភាគ SWOT នៃខេត្ត Aichi នៃប្រទេសជប៉ុន** • រចនាសម្ព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិនៃប្រទេសជប៉ុន • ការវិភាគ SWOT របស់ខេត្ត Aichi ប្រទេសជប៉ុន	លោកបណ្ឌិត **ខ៊ុំ ម៉េងហ៊ុយ** ទីប្រឹក្សាជាតិប្រចាំ អ.គ.ហ.	• យល់ដឹងពីរចនាសម្ព័ន្ធគ្រប់គ្រង និងការបែងចែកភារកិច្ចរវាងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៃប្រទេសជប៉ុន • បង្កើនចំណេះដឹងពាក់ព័ន្ធនឹងធាតុសំខាន់ៗនៃការវិភាគ SWOT ក្នុងការអនុវត្តជាក់ស្ដែង • យល់ដឹងអំពីវិធីសាស្ត្រក្នុងការពង្រឹងភាពខ្លាំង និងការបង្កើតឱ្យមានឱកាសសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច
០៩:៣០-១១:០០ (៩០នាទី)	**ការវិភាគ SWOT របស់មន្ទីរ សហវ.** • ព័ត៌មានរាជធានី-ខេត្ត (ទីតាំងភូមិសាស្ត្រ, ប្រជាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធ) • ទិដ្ឋភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច (កសិកម្ម, កម្មន្តសាល និងសេវាកម្ម, ទេសចរណ៍, និង វិស័យហិរញ្ញវត្ថុ) • ការវិភាគ SWOT ÷ សក្ដានុពល និងបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍របស់រាជធានី-ខេត្ត	តំណាងមន្ទីរ សហវ. រាជធានីភ្នំពេញ តំណាងមន្ទីរ សហវ. ខេត្តព្រះសីហនុ តំណាងមន្ទីរ សហវ.ខេត្តបន្ទាយមានជ័យ	• កំណត់បានប្រភពសម្រាប់ប្រមូលទិន្នន័យ • បទពិសោធន៍ក្នុងការរៀបចំការវិភាគ SWOT

១១:០០-១១:៤៥ (៤៥នាទី)	**ក្របខណ្ឌនៃការវិភាគ SWOT និងទិដ្ឋភាពប្រៀបធៀបផ្នែកសង្គម-សេដ្ឋកិច្ចនៅកម្រិតរាជធានី-ខេត្ត** • សារវតារនៃការវិភាគSWOT • ក្របខណ្ឌក្នុងការរៀបចំការវិភាគ SWOT • សូចនាករសំខាន់ៗក្នុងការពិនិត្យនិងប្រៀបធៀបផ្នែកសង្គម-សេដ្ឋកិច្ចកម្រិត រាជធានី-ខេត្ត • មតិយោបល់លើបទបង្ហាញមន្ទីរ សហវ.	លោកបណ្ឌិត **សំរិត សុវណ្ណារឿន** ទីប្រឹក្សាជាតិប្រចាំ អ.គ.ហ.	• ចំណេះដឹងស្ដីពីក្របខណ្ឌក្នុងការរៀបចំការវិភាគ SWOT • យល់ដឹងពីសូចនាករសំខាន់ៗក្នុងការប្រៀបធៀបផ្នែកសង្គម-សេដ្ឋកិច្ចរវាងរាជធានី-ខេត្ត • កំណត់បានចំណុចខ្វះខាតនៃការរៀបចំការវិភាគ SWOT របស់មន្ទីរ សហវ.
១១:៤៥-១២:៣០ (៤៥នាទី)	**<u>កិច្ចពិភាក្សា</u>** • ក្របខណ្ឌក្នុងការរៀបចំការវិភាគ SWOT • សូចនាករសង្គម-សេដ្ឋកិច្ចសម្រាប់ការវិភាគSWOT • មតិយោបល់លើបទបង្ហាញរបស់មន្ទីរ សហវ. • សំណួមពរ **<u>វាគ្មិន</u>** • លោកបណ្ឌិត **ខ៊ុវ ប៉េងហ៊ុយ** • លោកបណ្ឌិត **សំរិត សុវណ្ណារឿន**	សម្របសម្រួលដោយ លោក **អ៊ុំ យុទ្ធី** ប្រធានផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងត្រួតពិនិត្យនិងវាយតម្លៃ	• កំណត់បានចំណុចដែលត្រូវបណ្ដុះបណ្ដាលបន្ថែម
សម្រាកអាហារថ្ងៃត្រង់			
កម្មវិធីពេលរសៀល			
១៣:៣០-១៤:០០	**ចុះឈ្មោះ**		
១៤:០០-១៤:៤៥ (៤៥នាទី)	**ទស្សនាទាននៃគោលនយោបាយជាតិ ស្ដីពីផលិតភាពសេដ្ឋកិច្ចកម្ពុជា** • ទស្សនាទាននៃផលិតភាពសេដ្ឋកិច្ច • យន្តការស្ថាប័ន • ក្របខណ្ឌគោលនយោបាយ • ការត្រៀមខ្លួនរបស់ក្រសួង-ស្ថាប័ន ដើម្បីចូលរួមលើកកម្ពស់ផលិតភាពសេដ្ឋកិច្ចជាតិ	ឯកឧត្តម **ស៊ីសុវត្ថិ ជួងចំន្ទឆោ** អគ្គលេខាធិការ នៃអគ្គលេខាធិដ្ឋាន គណៈកម្មាធិការជាតិផលិតភាព សេដ្ឋកិច្ចកម្ពុជា	• លើកកម្ពស់ការយល់ដឹងពីក្របខណ្ឌផលិតភាពសេដ្ឋកិច្ចនៅកម្ពុជា
១៤:៤៥-១៥:៣០ (៤៥នាទី)	**ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥** • ការកសាងគ្រឹះ, សសរស្តម្ភ និងគោលការណ៍ • និយមន័យសេដ្ឋកិច្ចនិងសង្គមឌីជីថល • សក្ដានុពលនិងផលប៉ះពាល់នៃបរិវត្តកម្មឌីជីថលនិងការត្រៀមខ្លួនរបស់កម្ពុជា • អាទិភាពយុទ្ធសាស្ត្រនិងក្របខណ្ឌគោលនយោបាយ	លោក **យន ម៉ាលីមនេថ** មន្ត្រីជំនាញជាន់ខ្ពស់ផ្នែកថវិកា នៃ អ.គ.ហ.	• បង្កើនកម្រិតយល់ដឹងលើគោលនយោបាយរបស់រាជរដ្ឋាភិបាល
១៥:៣០-១៦:១៥ (៤៥នាទី)	**សេចក្តីព្រាងគេហទំព័រនិងទម្រង់បង្ហាញទិន្នន័យ** • ទម្រង់គំរូគេហទំព័រ • ប្រភេទទិន្នន័យ និងទម្រង់នៃការបង្ហាញទិន្នន័យ	លោក **ស៊ឹម ស៊ីណែត** មន្ត្រីគ្រប់គ្រងទិន្នន័យនិងអភិវឌ្ឍប្រព័ន្ធ នៃ អ.គ.ហ.	• មតិយោបល់ចុងក្រោយលើទម្រង់គេហទំព័រ និងទិន្នន័យ

			និងទម្រង់ក្នុងការបង្ហាញ លើគេហទំព័រ
១៦:១៣-១៧:០០ (៤៥នាទី)	<u>**កិច្ចពិភាក្សា**</u> • ផលិតភាពសេដ្ឋកិច្ចកម្ពុជា • ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គម ឌីជីថលកម្ពុជា ២០២១-២០៣៥ • ប្រភេទនិងទម្រង់បង្ហាញទិន្នន័យលើគេហទំព័រ • បញ្ហាប្រឈម និងសំណូមពរ • ជំហានបន្ទាប់លើការរៀបចំគេហទំព័រ <u>**វាគ្មិន**</u> • ឯកឧត្តម **ស៊ីសុវត្ថិ ដួងចំនួនោ** • លោក **យន ម៉ាលីមនេង** • លោក **ស៊ឹម ស៊ីណែត**	សម្របសម្រួលដោយលោក **អ៊ុំ យុទ្ធី** ប្រធានផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និង ត្រួតពិនិត្យនិងវាយតម្លៃ	• ឯកភាពលើទម្រង់គេហទំព័រ • ឯកភាពលើទិន្នន័យ និងទម្រង់ក្នុងការបង្ហាញទិន្នន័យ • កំណត់បានផែនការក្នុងការប្រមូលទិន្នន័យ
១៧:០០-១៧:៣០ (៣០នាទី)	**មតិបូកសរុប និង បិទអង្គសិក្ខាសាលា** • សំណូមពរ និងជំហានការងារបន្ទាប់	ឯកឧត្តម **យ៉េត វីណែល** អនុរដ្ឋលេខាធិការ កសហវ. និងជា អគ្គលេខាធិការរង អ.ឥ.ហ.	

<u>សម្គាល់</u>÷ អ.ឥ.ហ. សូមរក្សាសិទ្ធិក្នុងការកែប្រែរបៀបវារៈខាងលើក្នុងករណីចាំបាច់!

១

ការវិភាគ SWOT នៃខេត្ត Aichi
នៃប្រទេសជប៉ុន

Awareness Raising Workshop on SWOT Analysis

SWOT ANALYSIS OF AICHI PREFECTURE, JAPAN

PRESENTER: NGOV PENGHUY, PHD

DATE: 13 JULY 2021

FLOW OF PRESENTATION

1. Introduction to Administrative Structure of Local Governments in Japan
2. SWOT Analysis of AICHI Prefecture in Japan

ADMINISTRATIVE STRUCTURE OF LOCAL GOVERNMENT IN JAPAN



JAPAN

Total Population: 127.46 million
Total Area: 377,955 km^2

"To" : Tokyo-To (Tokyo Metropolis or Tokyo Prefecture in English) only

"Do" : Hokkai-Do (Hokkaido Prefecture in English) only

"Fu" : Osaka-Fu (Osaka Prefecture in English) only and Kyoto-Fu (Kyoto Prefecture in English) only

"Ken" : 43 ken (prefectures in English) in total

Total: 47 To-Do-Fu-Ken (Prefectures) in all



MUNICIPAL DISTRIBUTION MAP OF AICHI PREFECTURE

Total Population: 7.43 million
Total Area: 5,163 km^2

Cities: 38
Town: 14
Village: 2
Total: 54

(As of 1 Apr. 2013)



DIVISION OF ROLES AMONG NATIONAL, PREFECTURAL AND MUNICIPAL LEVELS OF GOVERNMENT

National Government		① Affairs of the nation that are consequential to its status as a member of the international community ② Administrative affairs concerning the activities of the people that should preferably be regulated in accordance with nationwide standards ③ Programs and services that need to be implemented/provided on a nationwide scale and from a nationwide viewpoint
Local governments		① Local administrative affairs ② Other admi nistrative affairs specified by laws and ordinances
	Prefectures	① Wide-area administrative affairs ② Administrative affairs concerning the liaison and coordination of municipalities ③ Administrative affairs considered beyond the capabilities of an ordinary municipality due to their scale or nature
	Municipalities	All administrative affairs other than those conducted by prefectures

DIVISION OF ROLES AMONG NATIONAL, PREFECTURAL AND MUNICIPAL LEVELS OF GOVERNMENT

National Government		1) Affairs of the nation that are consequential to its status as a member of the international community 2) Administrative affairs concerning the activities of the people that should preferably be regulated in accordance with nationwide standards 3) Programs and services that need to be implemented/provided on a nationwide scale and from a nationwide viewpoint
Local Governments		1) Local Administrative Affairs 2) Other Administrative affairs specified by law and ordinances
	Prefectures	1) Wide-area administrative affairs 2) Administrative affairs concerning the liaison and coordination of municipalities 3) Administrative affairs considered beyond the capabilities of an ordinary municipality due to their scale or nature
	Municipalities	All administrative affairs other than those conducted by prefectures

CONCRETE EXAMPLES OF DIVISION OF ROLES (1)

- Functional division among the national, prefectural and municipal levels of government in a common area, under which local governments perform most of the type of administrative processing that has immediate relevance to peoples' daily lives

Affairs		National	Prefectural/Metropolitan	Municipal
Residents' affairs				Family registers and residential basic book
Social welfare	Elderly	National Pension		Nursing insurance
	Unemployed	Job search support / Employment insurance	Vocational training	
	Destitute		Livelihood protection (residents of towns and villages)	Livelihood protection (residents of cities)
Public health and hygiene	Public health	Quarantine	Health examination and food hygiene	
	Medical care and pharmaceutical affairs	National hospitals (advanced medical care, etc.) Licensing of medical practitioners and approval of pharmaceuticals	Prefectural hospitals (advanced medical care, etc.)	Municipal hospitals National Health Insurance

8

CONCRETE EXAMPLES OF DIVISION OF ROLES (2)

Affairs		National	Prefectural	Municipal
Environ-ment	Regulation	Environmental quality standards	Environmental regulation and pollution monitoring	
	Waste management		Supervision of disposal of industrial wastes (private sector)	Disposal of general solid wastes
Industry	Industry and commerce	Trade policy Support for small and medium enterprises	Industrial land development and luring of businesses Support for small and medium enterprises	Promotion of local industries
	Agriculture	National land improvement projects Food security	Prefectural land improvement projects Improvement and dissemination of agricultural technologies	Municipal land improvement projects
Civil engineer-ing	Roads	Expressways / national highways	Prefectural roads / (national highways)	Municipal roads
	Rivers	Class 1 rivers (outside designated sections)	Class 1 rivers (designated sections) Class 2 rivers	Rivers other than class 1 or 2 rivers as designated by municipal mayors

9

CONCRETE EXAMPLES OF DIVISION OF ROLES (3)

Affairs		National	Prefectural	Municipal
Civil engineering	Ports and harbors		Ports and harbors	Ports and harbors
	Airports	Class 1 and 2 airport	Class 2 and 3 airport	Class 3 airport
Housing	Housing		Prefectural housing	Municipal housing
	Water-works			Waterworks
	Sewerage systems		River basin sewerage	Public sewerage
Public safety and security		National defense, trials and punishment	Police	Fire and ambulance services
Education		National universities and colleges Curriculum guidelines	Prefectural universities and colleges Senior high schools	Elementary schools and junior high schools (teachers' salaries to be paid by prefectures)

10

SWOT ANALYSIS OF AICHI PREFECTURE

STRENGTH

- High per capita income
- High proportion of residents in populated area.
- High population density in populated area.
- Low car ownership rate per family
- Low utilization rate of personal car
- Low disposal of garbage rate compared with other cities of similar size
- High prevalence of sewage system
- High maintenance of foundation
- Convenient facilities nearby

WEAKNESS

- High rate of population decrease in the future
- High proportion of aging population
- High ratio of government bond
- Low population size per family
- Small area of house and its available space
- Low number of nursing homes compared to the aging population
- Limited nature (forests, etc)

OPPORTUNITY

- Concentration of opulation to big cities
- Agglomoration of growing service industries in big cities
- Promotion of merging of cities, town, and villages
- Promotion of revitalization of cities
- Amendment of law on improving "green landscapte"
- Interst of having "compact city" by the people

THREAT

- Arrival of the age of population decrease
- Rapid speed of decreasing birth rate and aging population
- Frequent phenomenon of "heat island" or "heat wave"
- High maintenance cost of social capital stock (road, port, sewage, park, telecommunication, airport, dam, post office, etc).

	Strength	Weakness
Growth (Population, Economy, Administration)	High Per Capital Income	○ High rate of population decrease in the future ○ High proportion of aging population ○ High ratio of government bond
Environmental Burden (Housing, Transportation, Garbage, etc)	○ High proportion of residents in populated area. ○ High population density in populated area. ○ Low car ownership rate per family ○ Low utilization rate of personal car ○ High rate of people commuting to work and school from the city ○ Low disposal of garbage rate compared with other cities of similar size	○ Low population size per family
Quality of Life (Living Environment, Public Facilities, Nature)	○ High prevalence of sewage system ○ High maintenance of foundation ○ Convenient facilities nearby	○ Small area of house and its available space ○ Low number of nursing homes compared to the aging population ○ Limited nature (forests, etc)

POLICIES

Active Policy

- Formation of compact city and maintain population density
- Improved public transportation and keep low rate of car usage
- Effective use of existing city facilities (road, park, etc) to create attractiveness
- Improved urban space through the city revitalization policy

POLICIES

- Improved facilities for old people to move around
- Improved environment for people to raise children so that to curb the speed low decreasing birthrate.
- Use public space (parks, etc) to provide shelter during any natural disaters (earthquake, etc).

REFERENCES

- United Nations Centre for Regional Development (2014). Japanese admistrative system. URL: https://www.uncrd.or.jp/content/documents/1739Bangla%20Tra%202013_P1_Japanese%20Administrative%20System.pdf
- SWOT Analysis of Aichi Prefecture. Translation from Japanese.

URL: https://www.nup.or.jp/nui/user/media/document/investigation/h17/17-a.pdf

២

ការវិភាគ SWOT របស់មន្ទីរ សហវ. រាជធានីភ្នំពេញ

ទិដ្ឋភាពសង្គម-សេដ្ឋកិច្ចនៃ រាជធានីភ្នំពេញ និងការវិភាគ SWOT ដើម្បីកំណត់ពីសក្តានុពល និង បញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍

មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានីភ្នំពេញ

ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១

1

មាតិកា

១. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ចនៃរាជធានីភ្នំពេញ

២. ការវិភាគ SWOT ដើម្បីកំណត់ពីសក្តានុពល និងបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍

៣. សេចក្តីសន្និដ្ឋាន

2

១. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ច

១. ទិដ្ឋភាពសង្គម-សេដ្ឋកិច្ច



ព័ត៌មានទូទៅ: (2020)

- **<u>ទីតាំងភូមិសាស្ត្រ និងអកាសធាតុ:</u>**
- ផ្ទៃដីសរុប 692.46 គ.ម²
  - មាន ១៤ខណ្ឌ ១០៥សង្កាត់ និង៩៥៣ភូមិ
  - មានអាកាសធាតុក្តៅពេញមួយឆ្នាំ
  - កម្រិតសីតុណ្ហភាពចាប់ពី ១៨ដល់៣៨°C
  - មានរដូវចំនួនពីរ គឺ ÷
    - រដូវប្រាំង ចាប់ពីខែធ្នូ ដល់ខែឧសភា (រយៈពេល៦ ខែ)
    - រដូវវស្សា ចាប់ពីខែមិថុនា ដល់ខែវិច្ឆិកា (រយៈពេល ៦ ខែ)
- **<u>ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន:</u>**
  - ប្រវែងផ្លូវបានកសាងសរុប 2,801,934 ម
  - ~~និងភាគរយ~~

១. ទិដ្ឋភាពសង្គម-សេដ្ឋកិច្ច

- ប្រជាសាស្ត្រ:
  - ចំនួនគ្រួសារ÷ ៣១៩,២២៨ គ្រួសារ
  - ចំនួនប្រជាជន
    - សរុប÷ ១,៥៦១,១៥១ នាក់
    - ប្រុស÷ ៧៥៣,០៣៦ នាក់
    - ស្រី÷ ៨០៨,១១៥ នាក់
  - %នៃប្រជាជន
    - ក្រោមអាយុ ១៧ឆ្នាំ មានចំនួន÷ ៣២.៦៥%
    - អាយុលើស ៦០ឆ្នាំ មានចំនួន÷ ១០.៤១%
  - កំលាំងពលកម្មចំណាកស្រុក %នៃប្រជាជនអាយុ១៨ឆ្នាំឡើងមានចំនួន÷ ៤.១៥%

១. ទិដ្ឋភាពសង្គម-សេដ្ឋកិច្ច (ត.)

វិស័យកសិកម្ម:

- ប្រភេទដំណាំសំខាន់ក្នុងរាជធានីភ្នំពេញមានដូចជា÷ ស្រូវ, ដំណាំរយៈពេលវែង និងដំណាំរយៈពេលខ្លី
- %ប្រជាជនដែលធ្វើការក្នុងវិស័យកសិកម្ម ÷ 2.19%
- ផ្ទៃដីស្រែដែលមានប្រព័ន្ធធារាសាស្ត្រ÷ 1,590 ហ.ត
- ទិន្នផលស្រូវសរុប 13,142.1 តោន

១. ទិដ្ឋភាពសង្គម-សេដ្ឋកិច្ច (ត.)

វិស័យកសិកម្ម:

- និងទិន្នផលស្រូវជាមធ្យម 2.5 តោន/ ហ.ត
  - ខណ្ឌដង្កោ ទិន្នផលស្រូវសរុប 6144.6 តោន, 2.3 តោន/១ហ.ត
  - ខណ្ឌសែនសុខ ទិន្នផលស្រូវសរុប 1150 តោន, 3.8 តោន/១ហ.ត
  - ខណ្ឌពោធិ៍សែនជ័យ ទិន្នផលស្រូវសរុប 494 តោន, 1.9 តោន/១ហ.ត
  - ខណ្ឌជ្រោយចង្វារ ទិន្នផលស្រូវសរុប 1947 តោន, 1.4 តោន/១ហ.ត
  - ខណ្ឌព្រែកព្នៅ ទិន្នផលស្រូវសរុប 3406.5 តោន, 2.3 តោន/១ហ.ត

7

១. ទិដ្ឋភាពសង្គម-សេដ្ឋកិច្ច (ត.)

កម្មន្តសាល និងសកម្មភាពក្នុងវិស័យសេវាកម្ម:

- ប្រភេទសំខាន់នៃកម្មន្តសាល និងសេវាកម្ម
  - កាត់ដេរ
  - សម្ភារសំណង់
  - គ្រឿងបរិភោគ
  - អាជីវកម្មខ្នាតតូច(លក់បាយ គុយទាវ...)
  - ភោជនីយដ្ឋាន
  - សណ្ឋាគារ

8

១. ទិដ្ឋភាពសង្គម-សេដ្ឋកិច្ច (ត.)

កម្មន្តសាល និងសកម្មភាពក្នុងវិស័យសេវាកម្ម:

- រោងចក្រវិនិយោគក្នុងរាជធានីភ្នំពេញមាន(២០២១)
  - ចំនួន ៧៥៤ រោងចក្រ
  - និងមានពលករសរុបចំនួន ៣៩០,៨៧៧ នាក់
- ទីតាំងផលិត និងផ្តល់សេវាមាន (២០២០)
  - ចំនួន ៣៥,៤៣៣ ទីតាំង
  - និងមានអ្នកធ្វើការសរុបចំនួន ១១១,៦៣២ នាក់

9

១. ទិដ្ឋភាពសង្គម-សេដ្ឋកិច្ច (ត.)

វិស័យទេសចរណ៍:

- ប្រភេទទេសចរណ៍ដែលមានភាពទាក់ទាញក្នុងវិស័យទេសចរណ៍
  - ទេសចរណ៍បែបប្រវត្តិសាស្ត្រ
  - ទេសចរណ៍បែបវប្បធម៌
- ចំនួនអ្នកទេសចរសរុបក្នុងឆ្នាំ២០២០ មានចំនួន ៦៥៣.៥៥៧ នាក់
  - ទេសចរជាតិមានចំនួន ១៥០,៩០៩ នាក់
  - ទេសចរអន្តរជាតិមានចំនួន ៥០២,៦៤៨ នាក់

10

១. ទិដ្ឋភាពសង្គម-សេដ្ឋកិច្ច (ត.)

វិស័យទេសចរណ៍:

- ចំនួនទីតាំងទេសចរណ៍សរុបបច្ចុប្បន្នមានចំនួន ១២ ទីតាំង÷
  1. ព្រះបរមរាជវាំង
  2. សារមន្ទីរជាតិ
  3. រមយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រវត្តភ្នំ
  4. សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង
  5. សារមន្ទីរប្រល័យពូជសាសន៍ជើងឯក
  6. សួនសត្វភ្នំពេញសាហ្វារី
  7. ផ្សារធំថ្មី
  8. ផ្សារទួលទំពូង
  9. រមណីយដ្ឋានកោះដាច់
  10. សួនទឹកហ្គាឌិនស៊ីធី
  11. សួនកម្សាន្តដាយណូស័រអ៊ីឡាយ
  12. សួនកម្សាន្តភ្នំពេញហ្វានតាស៊ី

11

១. ទិដ្ឋភាពសង្គម-សេដ្ឋកិច្ច (ត.)

វិស័យហិរញ្ញវត្ថុ:

- ចំនួនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងរាជធានីភ្នំពេញ
  - មានចំនួន ៧០គ្រឹះស្ថាន (មិនគិតចំនួនសាខា)
- ចំនួនធនាគារឯកទេសក្នុងរាជធានីភ្នំពេញ
  - មានចំនួន ១៤ ធនាគារ (មិនគិតចំនួនសាខា)
- ចំនួនធនាគារពាណិជ្ជក្នុងរាជធានីភ្នំពេញ
  - មានចំនួន ៥១ ធនាគារ (មិនគិតចំនួនសាខា)

12

ការវិភាគ SWOT ដើម្បីកំណត់ពីសក្តានុពល និង បញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍

▶ 13

២. ការវិភាគ SWOT ដើម្បីកំណត់ពីសក្តានុពល និងបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍

	កត្តាវិជ្ជមាន	កត្តាអវិជ្ជមាន
ផ្នែកខាងក្នុង	១. មានការអភិវឌ្ឍន៍យ៉ាងឆាប់លើគ្រប់វិស័យ ២. ជាបណ្តុំនៃស្ថាប័នរដ្ឋ ឯកជន និងអាជីវកម្ម ៣. ចំនួនប្រជាជន	១. កត្តាបរិស្ថាន ២. បញ្ហាស្ទះ៣ ៣. ទំហំផ្ទៃដីតូច
ផ្នែកខាងក្រៅ	១. មធ្យាបាយដឹកជញ្ជូនសាធារណៈ ២. តំបន់សេដ្ឋកិច្ចពិសេស ៣. ការលើកទឹកចិត្តផ្នែកពន្ធដា	១. ការរីករាលដាលនៃជំងឺកូវិដ១៩ ២. តម្លៃអចលនទ្រព្យខ្ពស់ជាងតាមបណ្តាខេត្ត ៣. ការផ្គត់ផ្គង់ទឹក ភ្លើង មិនគ្រប់គ្រាន់

រាជធានីភ្នំពេញ

▶ 14

៣. សេចក្តីសន្និដ្ឋាន

15

៣. សេចក្តីសន្និដ្ឋាន

- រាជធានីភ្នំពេញគឺទីតាំងភូមិសាស្ត្រមួយដែលមានសក្តានុពលខ្ពស់ក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច និងជាទីតាំងដែលមានការអភិវឌ្ឍន៍ខ្លាំងជាងគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ភ្នំពេញជាទីប្រជុំជនដែលមានមនុស្សច្រើនកុះករ ជាបណ្តុំនៃស្ថាប័នរដ្ឋ ឯកជន អាជីវកម្ម និងសេវាកម្ម ហើយអគារធំៗ ខ្ពស់ៗ ជាច្រើនត្រូវបាន និងកំពុងសាងសងក្នុងទីតាំងភូមិសាស្ត្រមួយនេះផងដែរ។ បើទោះបីជាមានកត្តាអវិជ្ជមានចំនួនក៏ដោយ ភ្នំពេញក៏នៅតែអាចទាក់ទាញមនុស្ស ក៏ដូចជាអ្នកវិនិយោគពីជិតឆ្ងាយបានផងដែរ ដោយភ្នំពេញក៏ជាទីតាំងមានឱកាសការងារខ្ពស់ និងមានអភិវឌ្ឍន៍លើគ្រប់វិស័យ។ កត្តាវិជ្ជមានទាំងនេះហើយ ដែលធ្វើអោយរាជធានីភ្នំពេញក្លាយជាផ្នែកមួយដ៏សំខាន់ក្នុងការជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងជាបេះដូងនៃព្រះរាជាណាចក្រកម្ពុជា។
- ជាចុងក្រោយ រាជធានីភ្នំពេញ ត្រូវមានផែនការមេស្របទៅនឹងផែនការថ្នាក់ជាតិ សំរាប់ប្រទេសក្លាយជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

16

សូមអរគុណ!

Thank you very much!

ឯកសារយោង

- ឯកសារព័ត៌មានស្តីពីសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០២១ រាជធានីភ្នំពេញ
- សេចក្តីព្រាងរបាយការណ៍ប្រចាំឆមាសទី១ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលរាជធានីភ្នំពេញ ឆ្នាំ២០២១
- បញ្ជីឈ្មោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ យកពីវេបសាយធនាគារជាតិនៃកម្ពុជា
- បញ្ជីឈ្មោះធនាគារឯកទេស យកពីវេបសាយធនាគារជាតិនៃកម្ពុជា
- បញ្ជីឈ្មោះធនាគារពាណិជ្ជ យកពីវេបសាយធនាគារជាតិនៃកម្ពុជា

៣

ការវិភាគ SWOT របស់មន្ទីរ សហវ.
ខេត្តព្រះសីហនុ

ទិដ្ឋភាពសង្គម-សេដ្ឋកិច្ច នៃខេត្តព្រះសីហនុ
និងការវិភាគ SWOT ដើម្បីកំណត់ពីសក្ដានុពល
និងបញ្ហាប្រឈម ក្នុងកិច្ចអភិវឌ្ឍន៍
មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តព្រះសីហនុ

ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០២១

មាតិកា

១. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ចនៃខេត្តព្រះសីហនុ

២. ការវិភាគ SWOT ដើម្បីកំណត់ពីសក្ដានុពល និងបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍

៣. សេចក្ដីសន្និដ្ឋាន

១. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ចនៃខេត្តព្រះសីហនុ

១. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ច

ព័ត៌មានទូទៅ÷

- ទីតាំងភូមិសាស្ត្រ

ខេត្តព្រះសីហនុ ស្ថិតនៅប៉ែកនិរតីនៃប្រទេសកម្ពុជា ជាប់នឹងតំបន់ឆ្នេរ មានចម្ងាយ២៣០គីឡូម៉ែត្រ ពីរាជធានីភ្នំពេញតាមផ្លូវជាតិលេខ៤ មានចម្ងាយ២៦០គីឡូម៉ែត្រ តាមផ្លូវជាតិលេខ៣ និងមានផ្លូវដែកតភ្ជាប់ពីរាជធានីភ្នំពេញដោយឆ្លងកាត់តាមខេត្តកណ្ដាល ខេត្តតាកែវ និងខេត្តកំពត។

ខេត្តព្រះសីហនុ មានព្រំប្រទល់÷

- ខាងជើង ជាប់នឹងខេត្តកោះកុង
- ខាងកើត ជាប់នឹងខេត្តកំពត និងខេត្តកំពង់ស្ពឺ
- ខាងត្បូងនិងខាងលិច ជាប់នឹងឈូងសមុទ្រថៃឡង់ដ៍។

១. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ច (ត)



- **ទីតាំងភូមិសាស្ត្រ (ត)**

បច្ចុប្បន្ន **ខេត្តព្រះសីហនុ** បែងចែកជារដ្ឋបាលដែនដី ដែលមានស្រុកចំនួន០៣ និងក្រុងចំនួន០២ ក្នុងនោះមានឃុំចំនួន២៣, សង្កាត់ចំនួន០៦, ភូមិចំនួន១១១ និងកោះចំនួន៣២។

-ផ្ទៃដីសរុប	២.៦៥៨,៩០ គ.ម²
-ផ្ទៃដីគោក	២.៤៩៦,៥១ គ.ម²
-ផ្ទៃដីកោះ	១៦២,៣៩ គ.ម²
-ឆ្នេរសមុទ្រ	១៧៥,៨១ គ.ម²
-ផ្ទៃដីកសិកម្ម (ស្រែ)	១៦.៥៦៧ ហ.ត
-ផ្ទៃដីកសិកម្ម (ចំការ)	៣០.០០០ ហ.ត
-ផ្ទៃដីព្រៃឈើ	២៨៦.៤៩២ ហ.ត

១. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ច (ត)

- **ស្ថានភាពប្រជាសាស្ត្រ**

ខេត្តព្រះសីហនុ មានប្រជាពលរដ្ឋរស់នៅចំនួន ៤៨.៣៧២គ្រួសារ មានមនុស្សសរុប២២៣.២៨៦នាក់ (ស្ត្រីចំនួន ១១២.២៤១នាក់) និងដង់ស៊ីតេប្រជាជនមានៈ ៨៤,២៩នាក់/គម²។ (គិតត្រឹមខែ មីនា ឆ្នាំ២០២១)។

ភាគរយមនុស្សក្រុមអាយុ



១. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ច (ត)



១. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ច (ត)

- ស្ថានភាពអាកាសធាតុ

ស្ថានភាពធាតុអាកាសក្នុងខេត្តព្រះសីហនុ ដែលបានពិនិត្យ និងអង្កេតក្នុងរយៈពេល១០ឆ្នាំចុងក្រោយ នៅស្ថានីយ៍ឧតុនិយមក្រុងព្រះសីហនុ គិតជាមធ្យមមាន ÷

-កំរិតកំពស់ទឹកភ្លៀងមាន ២.៥៩០មម/ឆ្នាំ

-មធ្យមភាគសីតុណ្ហភាព អតិបរមា ៣១,៧អង្សាសេ អប្បបរមា ២៤,៦អង្សាសេ

-សំណើមនៅលើផ្ទៃដីមាន ៨៤,៩%

-ល្បឿនខ្យល់ ពី៤ទៅ៧ម/វិនាទី ដែលភាគច្រើនបក់មកពីទិសពាយ័ព្យ ។

១. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ច (ត)

- **ស្ថានភាពកសិកម្ម៖ ទិន្នន័យដើមឆ្នាំ២០១៩ ពីមន្ទីរកសិកម្ម**

- ប្រជាជនប្រមាណ១៦.៩២៦នាក់ ស្មើនឹង១៣,៣% មានមុខរបរធ្វើស្រែជាចម្បងនៃគ្រួសារប្រកបរបរកសិកម្មជាចម្បងសរុប។
- ការងារបង្កបង្កើនផលស្រូវវស្សា អនុវត្តបានលើផ្ទៃដី ១០.៥៩៨ហ.ត ស្មើនឹង៧៥,៧% នៃផែនការ១៤.០០០ហ.ត
- ទិន្នផលស្រូវជាមធ្យម ៣,២តោន/ហ.ត
- ដំណាំរួមផ្សំ និងបន្លែ អនុវត្តបានលើផ្ទៃដី ៣៦២ហ.ត ស្មើនឹង ៨០,៤៤% នៃផែនការ ៤៥០ហ.ត។
- ការវិនិយោគលើដំណាំកសិ-ឧស្សាហកម្ម
  - ដំណាំដូងប្រេងមានសរុបប្រមាណ ១៣.២៧៣ហ.ត ក្នុងនោះដីសម្បទានសេដ្ឋកិច្ចមានចំនួន ៦,២៧៣ហ.ត និងផ្ទៃដីឯកជនក្រុមហ៊ុនម៉ុងឫទ្ធីគ្រុប ៧.០០០ហត
  - ដំណាំកៅស៊ូមានប្រមាណ ៣.៨២១ហ.ត ក្នុងនោះការដាំជាលក្ខណៈគ្រួសារចំនួន ១.៣២១ហ.ត បានប្រមូលផលចំនួន ៧៥០ហ.ត និងក្រុមហ៊ុនម៉ុងឫទ្ធីគ្រុប កំពុងដំណើរការដាំដុះ ២.៥០០ហ.ត បានប្រមូលផល ១.១០០ហ.ត
  - ដំណាំកសិឧស្សាហកម្មផ្សេងៗទៀតមានចំនួន ១៣.៥០៧ហ.ត។
- **ការចិញ្ចឹមសត្វ ទាំងលក្ខណៈគ្រួសារ និងកសិដ្ឋាន គឺមានការអភិវឌ្ឍទាំងបរិមាណសត្វ និងតាមបែបផលិតកម្ម។**

១. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ច (ត)

- **ស្ថានភាពជលផល៖ ទិន្នន័យឆ្នាំ២០១៩ ពីខណ្ឌរដ្ឋបាលជលផល**

- ទូកនេសាទលក្ខណៈសិប្បកម្ម មានចំនួន ១.៦៥០គ្រឿង (កម្លាំងម៉ាស៊ីនលើ៣៣សេះ មានចំនួន២៩០គ្រឿង និងកម្លាំងម៉ាស៊ីនក្រោម៣៣សេះ មានចំនួន១.៣៦០គ្រឿង) បានប្រើប្រាស់កម្លាំងពលកម្មនេសាទចំនួន ១.៦៣០គ្រួសារ ស្មើនឹងចំនួនមនុស្ស ១.៨០០នាក់
- ទូកនេសាទលក្ខណៈគ្រួសារមានម៉ាស៊ីនកម្លាំងក្រោម ១៣សេះ មានចំនួន ១.០៩៥គ្រឿង និងទូកគ្មានម៉ាស៊ីន (ទូកចែវ) ចំនួន ២០គ្រឿង មានអ្នកនេសាទចំនួន ៥.៥០០គ្រួសារ ប្រើប្រាស់កម្លាំងពលកម្មចំនួន ៨.០៦០នាក់
- ផលត្រីទឹកសាបតាមវាលស្រែបានចំនួន ៣៣៦តោន ប្រើប្រាស់កម្លាំងពលកម្មនេសាទចំនួន ៨.២០០គ្រួសារ ស្មើនឹងចំនួនមនុស្ស ១៣.៦០០នាក់
- វារីវប្បកម្មមានគ្រួសារចិញ្ចឹមត្រី បង្គា អត្រា ០,២១%
- សិប្បកម្មកែច្នៃផលនេសាទមានចំនួន ១០កន្លែង
- សិប្បកម្មផលិតទឹកត្រីមានចំនួន ២កន្លែង
- ការនាំចេញផលិតផលនេសាទស្រស់ចំនួន ២.៩៨០តោន។

៩. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ច (ត)



៩. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ច (ត)

- **ស្ថានភាពគមនាគមន៍និងដឹកជញ្ជូន**

ប្រព័ន្ធគមនាគន៍ និងដឹកជញ្ជូន ក្នុងខេត្តព្រះសីហនុ ÷

-**ផ្លូវគោក**÷ មានផ្លូវដែក ផ្លូវជាតិលេខ៤ ផ្លូវជាតិលេខ៣

-**ផ្លូវទឹក** ÷ មានកំពង់ផែធំៗចំនួន៣ គឺកំពង់ផែស្វយ័តក្រុងព្រះសីហនុ ឧកញ៉ាម៉ុង អន្តរជាតិស្ទឹងហាវ

-**ផ្លូវអាកាស** ÷ មានអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ

-មានក្រុមហ៊ុនដឹកជញ្ជូន ÷

--ក្រុមហ៊ុនដឹកអ្នកដំណើរផ្លូវគោកមានចំនួន ១៤ក្រុមហ៊ុន

--ក្រុមហ៊ុនដឹកអ្នកដំណើរផ្លូវដែកមានចំនួន ១ក្រុមហ៊ុន

--ក្រុមហ៊ុនដឹកអ្នកដំណើរផ្លូវទឹកមានចំនួន ៨ក្រុមហ៊ុន

--ក្រុមហ៊ុនដឹកអ្នកដំណើរផ្លូវអាកាសមានចំនួន ១១ក្រុមហ៊ុន

--ក្រុមហ៊ុនដឹកជញ្ជូនទំនិញមានចំនួន ៤២ក្រុមហ៊ុន

--ក្រុមហ៊ុនតាក់ស៊ីមានចំនួន ២ក្រុមហ៊ុន

១. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ច (ត)

- **ស្ថានភាពឧស្សាហកម្ម និងសិប្បកម្ម**

-វិស័យឧស្សាហកម្ម ÷ រោងចក្រសរុបមានចំនួន ២១០រោងចក្រ មានពលករសរុបចំនួន ៣៨.៣៣១នាក់ (ស្រីចំនួន ២៤.៩៩៦នាក់) និងមានទុនវិនិយោគសរុបចំនួន ១.៣៤០.១៧២.៣២៣$ ក្នុងនោះ

--តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ មានចំនួន ១៦១រោងចក្រ

--តំបន់សេដ្ឋកិច្ចកំពង់ផែស្វយ័តក្រុងព្រះសីហនុ មានចំនួន ៣រោងចក្រ

--តំបន់សេដ្ឋកិច្ចពិសេសចេជាង (ស្រុកព្រៃនប់) មានចំនួន ៦រោងចក្រ

--ក្រៅតំបន់សេដ្ឋកិច្ចពិសេស មានចំនួន ៤០រោងចក្រ

-សហគ្រាសធុនតូច មធ្យម និងសិប្បកម្ម ÷ សរុបមានចំនួន ១.០៣៧មូលដ្ឋាន មានពលករសរុបចំនួន ៣.៥១២នាក់ (ស្រីចំនួន ៧១៩នាក់) និងមានទុនវិនិយោគសរុបចំនួន ១៥.៩៤២.៧០០$

-មូលដ្ឋានផលិតទឹកស្អាតក្នុងខេត្ត មានចំនួន ៨មូលដ្ឋាន។

១. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ច (ត)

- **ធនធានរ៉ែ និងថាមពល**

-ការងារថាមពល ÷ មានរោងចក្រអគ្គិសនីដើរដោយធ្យូងថ្មចំនួន ២រោងចក្រ

-ការងារប្រេងកាត ÷ -មានប្លុកប្រេងកាតក្នុងសមុទ្រចំនួន ៤ប្លុក (A,B,C,D)

-មានរោងចក្រចម្រាញ់ប្រេងកាតចំនួន ១រោងចក្រ

-មានកន្លែងសន្និធិប្រេងធំៗចំនួន ៥កន្លែង (Sokimex, Tela, Caltex, LHR, PTT)

-ការងារអគ្គិសនី ÷ ការប្រើប្រាស់អគ្គិសនីមានអត្រាប្រមាណ ៩៦,០៥% នៃចំនួនផ្ទះសរុបក្នុងខេត្ត

(នៅសល់ដោយសារមានគ្រួសាររស់នៅតាមភូមិដាច់ស្រយាល និងនៅតាមទីកោះ)

១. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ច (ត)

- **ស្ថានភាពទេសចរណ៍÷ ទិន្នន័យឆ្នាំ២០១៩ ពីមន្ទីរទេសចរណ៍**

-វិស័យទេសចរណ៍÷ ខេត្តព្រះសីហនុ ត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាប៉ូលទេសចរណ៍ដ៏សំខាន់មួយក្នុងចំណោម ប៉ូលទេសចរណ៍សំខាន់ៗរួមមាន÷ រាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តតំបន់ឆ្នេរសមុទ្រ និងខេត្តភាគឦសាន ហើយបានប្រសិទ្ធនាមថាជា “តារារះនាទិសនារតី” គឺពិតជាស័ក្តិសមបំផុតសម្រាប់ខេត្តព្រះសីហនុ ក្នុងចំណោមខេត្តឆ្នេរសមុទ្រទាំងបួន។

-ខេត្តព្រះសីហនុ មានតំបន់អភិវឌ្ឍន៍ទេសចរណ៍ទាក់ទាញជាច្រើនដូចជាឆ្នេរខ្សាច់ស កោះស្រស់ស្អាត រមណីយដ្ឋានធម្មជាតិ និងជីវៈចម្រុះជាច្រើន ក្នុងនោះក៏មានសម្បទាទេសចរណ៍ និងសម្បទាផ្គត់ផ្គង់ផ្សេងៗទៀត ដូចជា÷

--សណ្ឋាគារ ១០៧កន្លែង --បឹងហ្គាឡូ ៣៣កន្លែង --ផ្ទះសំណាក់ ២៣០កន្លែង

--បៀរហ្គាឌែន ៣កន្លែង --ឌីស្កូតែក ៩កន្លែង --ខារ៉ាអូខេ ៣៨កន្លែង

--ភោជនីយដ្ឋាន ៣១៧កន្លែង --ម៉ាស្សាសុខភាព ៦៦កន្លែង --កីឡាទេសចរណ៍ ២០កន្លែង

--រមណីយដ្ឋាន/កន្លែងកំសាន្ត ២០កន្លែង --ទីភ្នាក់ងារទេសចរណ៍ ២៣កន្លែង (ភាគច្រើនតូចៗជាលក្ខណៈគ្រួសារ)

*** កម្លាំងពលកម្មកំពុងបម្រើការក្នុងវិស័យទេសចរណ៍សរុបចំនួន ១៧.២១៥នាក់ (ស្រីចំនួន ៩.១៦៥នាក់)

*** ទទួលបានភ្ញៀវទេសចរណ៍សរុបរួម ចំនួន ២.២២៩.៤៨២នាក់ កើនឡើង៨,៨៧% ធៀបនឹងឆ្នាំ២០១៨ ក្នុងនោះភ្ញៀវទេសចរណ៍ជាតិមានចំនួន ១.៣៤៣.៦៩០នាក់ និងភ្ញៀវអន្តរជាតិ មានចំនួន ៨៨៥.៧៩២នាក់។

១. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ច (ត)

- **ស្ថានភាពប្រៃសណីយ៍និងទូរគមនាគមន៍**

-ខេត្តព្រះសីហនុ÷ មាន

--បញ្ជរប្រៃសណីយ៍ចំនួន ៥ ស្ថិតនៅក្នុងក្រុងព្រះសីហនុ

--ក្រុមហ៊ុនទូរស័ព្ទចល័តចំនួន ៥ និងអចល័តចំនួន ២

--ក្រុមហ៊ុនអ៊ីនធើណែតចល័តចំនួន ៣ និងអចល័តចំនួន ១១

--ស្ថានីយ៍ខ្សែកាប្លិ៍បាតសមុទ្រចំនួន ២ (Telcotech និង CFOCN)

១. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ច (ត)

- **ស្ថានភាពពាណិជ្ជកម្ម**

-វិស័យពាណិជ្ជកម្ម÷ ក្រៅពីការនាំទំនិញចេញ-ចូលក្នុង និងក្រៅប្រទេសតាមច្រកកំពង់ផែ ខេត្តព្រះសីហនុ បាននិងកំពុងកែលម្អបរិយាកាសធុរកិច្ច និងវិនិយោគ ជាពិសេសពន្លឿនការផ្តល់សេវាពាណិជ្ជកម្ម និងការចរចាបើកទីផ្សារថ្មីៗបន្ថែមទៀត សម្រាប់ផលិតផលទំនិញរបស់កម្ពុជា។ បច្ចុប្បន្ន ខេត្តព្រះសីហនុ មាន÷

--ផ្សារតូចធំក្នុងក្រុងចំនួន ៨ទីតាំង

--ផ្សារទំនើបក្នុងក្រុងចំនួន ៣៨ទីតាំង

--ផ្សាររាត្រីនៅក្នុងក្រុង និងផ្សារតាមបណ្តាស្រុកទាំង៣

--ការតាំងពិព័រណ៍ពាណិជ្ជកម្ម

១. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ច (ត)

- **វិស័យឯកជន**

-វិស័យឯកជន÷ រាជរដ្ឋាភិបាល បានកំណត់ថាវិស័យឯកជន គឺជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច។

-គម្រោងវិនិយោគនានាដែលដំណើរការនៅក្នុងដែនដីខេត្តព្រះសីហនុ មានដូចខាងក្រោម÷

-វិស័យកសិកម្ម និងកសិឧស្សាហកម្ម មានចំនួន ១៤ក្រុមហ៊ុន/គម្រោង

--សរុបទុនវិនិយោគចំនួន ១.១៦៨.៦២២.៥៩៤$

-ប្រតិបត្តិការ និងអាជីវកម្មធនធានរ៉ែ មានចំនួន ៦ក្រុមហ៊ុន/គម្រោង

--សរុបទុនវិនិយោគចំនួន ៥១.៧០៨.៣១០$

-វិស័យកម្មន្តសាល (វាយនភណ្ឌ កែច្នៃម្ហូបអាហារ ផលិតភេសជ្ជៈ កែច្នៃឈើ និងផលិតផលពីឈើ កែច្នៃកៅស៊ូ និងប្លាស្ទិក កែច្នៃលោហធាតុមូលដ្ឋាន កែច្នៃបរិក្ខារដឹកជញ្ជូន កែច្នៃគ្រឿងសង្ហារឹម ផលិតហ្វីល) មានចំនួន ២៩ក្រុមហ៊ុន/គម្រោង

-- សរុបទុនវិនិយោគចំនួន ២៣៥.៥១៦.៩៩១$

-វិស័យសំណង់ មានចំនួន ១១ក្រុមហ៊ុន

-- សរុបទុនវិនិយោគចំនួន ១.០៥៦.៥០០.០០០$

-វិស័យសេវាកម្មស្នាក់នៅ ផ្សារទំនើប អភិវឌ្ឍន៍តំបន់ទេសចរណ៍ និងអាហារ មានចំនួន ៣៣ក្រុមហ៊ុន/គម្រោង

-- សរុបទុនវិនិយោគចំនួន ៧.០៩១.១៣១.៣៧៥$

-សេវាកម្មច្បាប់ និងគណនេយ្យ មានចំនួន ១ក្រុមហ៊ុន

-- សរុបទុនវិនិយោគចំនួន ១.០៤០.០០០$

១. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ច (ត)

- **វិស័យធនាគារ និងហិរញ្ញវត្ថុ**

-**វិស័យធនាគារ និងហិរញ្ញវត្ថុក្នុងខេត្តព្រះសីហនុ**÷ សម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដែលមានដូចជា កំណើនឥណទាន ការផ្តល់ប្រាក់កម្ចី និងការយល់ដឹងរបស់វិនិយោគិន សិប្បករ អាជីវករ កសិករ និងប្រជាពលរដ្ឋ លើវិស័យហិរញ្ញវត្ថុ។ ខេត្តព្រះសីហនុ មាន÷

--ធនាគារជាតិនៃកម្ពុជា សាខាខេត្តព្រះសីហនុ ចំនួន ១ទីតាំង

--ធនាគារឯកជន ចំនួន ១៩ទីតាំង

--គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឯកជន ចំនួន ១២ទីតាំង

១. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ច (ត)

- **ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ក្នុងរយៈពេល៥ឆ្នាំ (២០១៣-២០១៧)**

-ផ្លូវលំជនបទដែលប្រើប្រាស់ថវិកាមូលនិធិឃុំ-សង្កាត់÷

--ធ្វើផ្លូវចាក់បេតុងអាមេរ៉ បានប្រវែង ៩.០១១ម

--ធ្វើផ្លូវលំគ្រួសធម្មជាតិ និងដាក់លូ បានប្រវែង ១០៨.៧១៩ម

-គម្រោងអភិវឌ្ឍន៍របស់រដ្ឋបាលខេត្ត÷

--ធ្វើផ្លូវចាក់បេតុងអាមេរ៉ បានប្រវែង ៥៥.៧៤៧ម

--អ៊ុតផ្លូវកៅស៊ូ DBST និងAC បានប្រវែង ១៨.៦០៨ម

--ជួសជុលលប់គ្រលុកសំបុកមាន់ បានប្រវែង ១៦.៨៧០ម

--សាងសង់លូរំដោះទឹក បានប្រវែង ៧.៨៥២ម

--ផ្សេងៗ.....

-គម្រោងរបស់មន្ទីរសាធារណការនិងដឹកជញ្ជូន÷

--សាងសង់និងជួសជុលផ្លូវ បានប្រវែង ១៩.១៧៥ម

--ពង្រីកផ្លូវ បានប្រវែង ១៤.២២០ម

--ផ្សេងៗ.....

១. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ច (ត)



១. ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ច (ត)

- ប្រភពសក្តានុពលសំខាន់ៗ

ខេត្តព្រះសីហនុ មានប្រភពសក្តានុពលដ៏សម្បូរបែប ដែលមានដូចខាងក្រោម÷

-តំបន់អភិវឌ្ឍន៍កសិកម្ម (ផ្ទៃដីស្រែ ចម្ការ ដំណាំ កសិ-ឧស្សាហកម្ម)

-តំបន់អភិវឌ្ឍន៍ទេសចរណ៍ (រមណីយដ្ឋានធម្មជាតិ តំបន់កោះ និងឆ្នេរខ្សាច់)

-តំបន់អភិវឌ្ឍន៍ពាណិជ្ជកម្ម (តំបន់សេដ្ឋកិច្ចពិសេស កំពង់ផែអន្តរជាតិ កំពង់ផែឧកញ៉ាម៉ុង កំពង់ផែអន្តរជាតិស្ទឹងហាវ និងក្រុមហ៊ុននាំចេញ- នាំចូលក្នុងនិងក្រៅប្រទេស)

-តំបន់អភិវឌ្ឍន៍ឧស្សាហកម្ម (រោងចក្រ សហគ្រាស អគ្គិសនី ទឹកស្អាត)

-វិស័យអចលនទ្រព្យ និងសំណង់

-វិស័យសណ្ឋាគារ និងកាស៊ីណូ

២. ការវិភាគ SWOT ដើម្បីកំណត់ពីសក្តានុពល និងបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍

២. ការវិភាគ SWOT ដើម្បីកំណត់ពីសក្តានុពល និងបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍

កត្តាវិជ្ជមាន | **កត្តាអវិជ្ជមាន**

កត្តាខាងក្នុង

ភាពខ្លាំង
1. ប្រព័ន្ធគមនាគមន៍សំបូរបែប
2. តំបន់សេដ្ឋកិច្ចពិសេសពហុបំណង
3. ប៉ូលទេសចរណ៍ ធុរៈកិច្ច និងលំហែ

ភាពខ្សោយ
1. កង្វះប្រព័ន្ធផ្សព្វផ្សាយ
2. កង្វះកំលាំងពលកម្មមានជំនាញ
3. ការផ្តល់សេវាសាធារណៈនៅមានកម្រិត

ខេត្តព្រះសីហនុ

កត្តាខាងក្រៅ

ឱកាស
1. ទីផ្សារការងារសំបូរបែប
2. វិនិយោគវិស័យទេសចរណ៍
3. វិនិយោគវិស័យអចលនទ្រព្យ

ការគំរាមកំហែង
1. គ្រោះធម្មជាតិ
2. តំបន់ការពារធម្មជាតិ
3. កង្វះប្រព័ន្ធធារាសាស្ត្រ

២. ការវិភាគ SWOT ដើម្បីកំណត់ពីសក្តានុពល និងបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍ (ត)

- **ភាពខ្លាំង**
  - **ប្រព័ន្ធគមនាគមន៍សំបូរបែប÷** មានផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស មានជាអាទិ៍÷ ផ្លូវថ្នល់ខ្វាត់ខ្វែង ផ្លូវទេសចរណ៍តាមបណ្តោយឆ្នេរ ផ្លូវដែក **កំពង់ផែអន្តរជាតិ** និងអាកាសយានដ្ឋានអន្តរជាតិក្រុងព្រះសីហនុ។
  - **តំបន់សេដ្ឋកិច្ចពិសេសពហុបំណង÷** មានការអភិវឌ្ឍន៍លើវិស័យនាំចេញ នាំចូលទាំងក្នុង និងក្រៅប្រទេស ដោយផ្អែកតាមច្រកកំពង់ផែអន្តរជាតិ កំពង់ផែឧកញ៉ាម៉ុង និងកំពង់ផែអន្តរជាតិស្ទឹងហាវ សម្រាប់ធ្វើការលើកដាក់ និងស្តុកទំនិញតាមស្តង់ដាអន្តរជាតិ ព្រមជាមួយនេះដែរក៏មានយន្តការត្រួតពិនិត្យទំនិញ និងផលិតផលដែលលក់នៅ ទីផ្សារមានការប្រើប្រាស់សារធាតុគីមីពុល ហួសកាលបរិច្ឆេទ និងក្លែងបន្លំ ដើម្បីការពារសុខភាពប្រជាពលរដ្ឋទាំងអ្នកផលិត និងអ្នកប្រើប្រាស់។
  - **ប៉ូលទេសចរណ៍ធុរៈកិច្ច និងលំហែ÷** មានឆ្នេរខ្សាច់ស កោះស្រស់ស្អាត ខ្យល់អាកាសបរិសុទ្ធ រមណីដ្ឋានធម្មជាតិ និងជីវៈចម្រុះជាច្រើន មានសណ្ឋាគារ(ផ្កាយប្រាំ) កាស៊ីណូ និងមជ្ឈមណ្ឌលកំសាន្តជាច្រើន និងមានការតាំងពិពណ៌ផ្សេងៗ។

២. ការវិភាគ SWOT ដើម្បីកំណត់ពីសក្តានុពល និងបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍ (ត)

- **ភាពខ្សោយ**
  - **ប្រព័ន្ធផ្សព្វផ្សាយនៅមានកម្រិត÷** ដែលធ្វើអោយប្រជាពលរដ្ឋ ក៏ដូចជាភ្ញៀវជាតិនិងអន្តរជាតិ មិនទាន់អាចទទួលបានព័ត៌មានគ្រប់បែបយ៉ាង និងគ្រប់ជ្រុងជ្រោយ អំពីស្ថានភាពខេត្តព្រះសីហនុ
  - **កង្វះកំលាំងពលកម្មមានជំនាញ÷** មិនទាន់មានកន្លែងបណ្តុះបណ្តាលចំណេះដឹងទូទៅ និងជំនាញវិជ្ជាជីវៈប្រកបដោយគុណភាពនៅឡើយ ទើបធ្វើអោយយើងបាត់បង់នូវឱកាសការងារល្អៗ
  - **ការផ្តល់សេវាសាធារណៈ÷** មិនទាន់បានល្អប្រសើរ ជូនដល់ប្រជាពលរដ្ឋ និងធុរជន។

២. ការវិភាគ SWOT ដើម្បីកំណត់ពីសក្តានុពល និងបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍(ត)

- **ឱកាស**
  - **ទីផ្សារការងារ** ÷ ដោយសារការរីកចំរើនដ៏លឿននិងស្ទើរគ្រប់វិស័យរបស់ខេត្តព្រះសីហនុ បាន និងកំពុងផ្តល់ឱកាសការងារយ៉ាងច្រើន និងសម្បូរបែបដល់ប្រជាពលរដ្ឋក្នុងខេត្ត ក៏ដូចជាតាមបណ្តាខេត្តដទៃ
  - **វិនិយោគវិស័យទេសចរណ៍** ÷ ខេត្តព្រះសីហនុត្រូវបានរាជរដ្ឋាភិបាលកំណត់ជាប៉ូលទេសចរណ៍ដ៏សំខាន់មួយក្នុងចំណោមប៉ូលទេសចរណ៍សំខាន់ទាំងបួន និងបានប្រសិទ្ធិនាម"**តារារះនាទិសនិរតី**"។ ខេត្តមានឆ្នេរខ្សាច់សកោះស្រស់ស្អាត មានជីវៈចម្រុះជាច្រើន និងការកំសាន្តដ៏សម្បូរបែប ដែលជាសក្តានុពលក្នុងការទាក់ទាញការមកលំហែរកំសាន្ត និងការវិនិយោគ
  - **វិនិយោគវិស័យអចលនទ្រព្យ** ÷ ដោយសារកំណើនសេដ្ឋកិច្ច និងសក្តានុពលជាច្រើនរបស់ខេត្ត បានធ្វើអោយវិស័យអចលនទ្រព្យ ក្លាយទៅជាចំណាប់អារម្មណ៍មួយដែលមិនអាចមើលរំលងបាន។

២. ការវិភាគ SWOT ដើម្បីកំណត់ពីសក្តានុពល និងបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍(ត)

- **ការគំរាមកំហែង**
  - **គ្រោះធម្មជាតិ** ÷ មានដូចជា ទឹកជំនន់ ខ្យល់គួច ឥទ្ធិពលព្យុះសមុទ្រ និងរន្ទះ ដែលខេត្តជួបប្រទះកន្លងមកបានបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្ស សត្វ ខូចខាតផលដំណាំកសិកម្ម ទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ និងប៉ះពាល់ដល់សេដ្ឋកិច្ចខេត្តផងដែរ
  - **តំបន់ការពារធម្មជាតិ** ÷ មានការចូលទន្ទ្រានកាន់កាប់ដី ការកាប់បំផ្លាញព្រៃឈើក្នុងតំបន់ការពារ ខ្វះការយល់ដឹងពីសារសំខាន់នៃធនធានព្រៃឈើ និងតំបន់ការពារធម្មជាតិមួយចំនួន បានគ្របដណ្តប់ទាំងផ្ទៃដីលំនៅឋាន និងដីស្រែចម្ការរបស់ប្រជាពលរដ្ឋ
  - **កង្វះប្រព័ន្ធធារាសាស្ត្រ** ÷ បរិមាណទឹកស្រោចស្រពមិនគ្រប់គ្រាន់នៅរដូវប្រាំង ប្រព័ន្ធរំដោះទឹកលក្ខណៈធម្មជាតិ មិនទាន់គ្រប់គ្រាន់ដែលធ្វើអោយខេត្តមានការលិចលង់ជារឿយៗ។

៣. សេចក្ដីសន្និដ្ឋាន

៣. សេចក្ដីសន្និដ្ឋាន

- **ខេត្តព្រះសីហនុ** មានវិស័យសេដ្ឋកិច្ចសំខាន់ៗ÷ វិស័យឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍ និងកសិកម្ម ដែលជាវិស័យគោលដៅសម្រាប់ការអភិវឌ្ឍន៍ខឿនសេដ្ឋកិច្ចជាតិរបស់រាជរដ្ឋាភិបាល។ ប្រភពសក្ដានុពលរួមមាន÷ **កំពងផែសមុទ្រទឹកជ្រៅ តំបន់សេដ្ឋកិច្ចពិសេស អាកាសយានដ្ឋានអន្តរជាតិ និងឆ្នេរដ៏ស្រស់ស្អាត។** សក្ដានុពល និងធនធានធម្មជាតិទាំងអស់ បាននិងកំពុងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចខេត្តឱ្យមានភាពរីកចម្រើនជាលំដាប់។
- បច្ចុប្បន្នខេត្តព្រះសីហនុ បាននិងកំពុងអនុវត្តនូវកិច្ចការជាច្រើនឱ្យសម្រេចបាននូវគោលនយោបាយរបស់រាជរដ្ឋាភិបាល ដើម្បីប្រែក្លាយខេត្តព្រះសីហនុទៅជា "**តំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង**" និងជាខេត្តទេសចរណ៍ជាប់មាត់សមុទ្រ ដែលមានឈ្មោះជា "**ទីក្រុងឧស្សាហកម្មបៃតងអាស៊ាន**" យ៉ាងយូរត្រឹមឆ្នាំ ២០២៥។
- ខេត្ត "**តារារះនាទិសនារតី**" មួយនេះ ទៅថ្ងៃអនាគត នឹងក្លាយទៅជាប៉ូលសេដ្ឋកិច្ចដ៏សំខាន់មួយ និងជាមជ្ឈមណ្ឌលឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ ដែលរីកចម្រើន "**ប្រកបដោយចីរភាព និងមានតុល្យភាពបរិស្ថាន**"។

៣. សេចក្តីសន្និដ្ឋាន (ត)

- ដើម្បីសម្រេចបានគោលដៅប្រកបដោយមហិច្ឆតានេះ គឺត្រូវទាមទារអោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការអនុវត្តការងារប្រកបដោយស្មារតីបុរេសកម្ម សកម្ម និងអន្តរសកម្ម ព្រមទាំងយកអស់ទាំងកម្លាំងកាយ-ចិត្ត-បេះដូង និងកែប្រែបញ្ហាប្រឈមក៏ដូចជាច្នៃការគំរាមកំហែងមួយចំនួនអោយទៅជាកាលានុវត្តភាព។
- បញ្ហាចំពោះមុខដែលត្រូវពង្រឹង និងដោះស្រាយមានដូចខាងក្រោម÷
  - **បង្កើន និងពង្រីក**ប្រសិទ្ធភាពនៃប្រព័ន្ធផ្សព្វផ្សាយពីសក្តានុពលរបស់ខេត្តព្រះសីហនុ អោយបានទៅដល់សាធារណជនទាំងក្នុងប្រទេស ក្នុងតំបន់ និងកម្រិតពិភពលោកទាំងមូល ដើម្បីទាក់ទាញការចាប់អារម្មណ៍ផ្សេងៗ
  - **បង្កើត និងពង្រឹង**មូលដ្ឋានបណ្តុះបណ្តាលនៅក្នុងខេត្តព្រះសីហនុ ទាំងចំណេះដឹង និងជំនាញវិជ្ជាជីវៈប្រកបដោយគុណភាព និងមានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ដើម្បីប្រកួតប្រជែងទីផ្សារការងារជំនាញ
  - **កែលម្អ និងពង្រឹង**គុណភាពនៃការផ្តល់សេវាសាធារណៈគ្រប់ប្រភេទ អោយបានកាន់តែមានប្រសិទ្ធភាព ទាន់ពេលវេលា និងទទួលខុសត្រូវខ្ពស់ និងត្រូវពង្រីកការផ្សព្វផ្សាយអំពីព័ត៌មានផ្សេងៗទាក់ទងនឹងការផ្តល់សេវាសាធារណៈអោយបានទូលំទំលាយ និងបានដឹងលឺដល់គ្រប់សាធារណជន
  - **ទប់ស្កាត់**ការកាប់បំផ្លាញនិងទន្ទ្រានគ្រប់រូបភាព នៅក្នុងតំបន់អភិរក្សធនធាន ជីវៈចម្រុះ និងព្រៃឈើ ដើម្បីធានាបាននូវនិរន្តភាពនៃការប្រើប្រាស់ និងតុល្យភាពបរិស្ថាន
  - **បង្កើត**ប្រព័ន្ធធារាសាស្រ្តបន្ថែមអោយបានគ្រប់គ្រាន់ ដើម្បីជាគុណប្រយោជន៍ដល់ដំណាំកសិកម្ម និងការពារបាននូវគ្រោះធម្មជាតិផ្សេងៗ។

ឯកសារយោង

- សេចក្តីសម្រេចលេខ ០៣៣/២១ ស.ស.រ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០២១ ស្តីពី ការដាក់អោយប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២១-២០២៣) របស់រដ្ឋបាលខេត្តព្រះសីហនុ
- សេចក្តីសម្រេចលេខ ០៣៨/២០ ស.ស.រ ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០២០ ស្តីពី ការដាក់អោយប្រើប្រាស់ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២០ - ២០២៤) របស់រដ្ឋបាលខេត្តព្រះសីហនុ
- អនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០២១ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការបច្ចេកទេសអន្តរក្រសួង រៀបចំគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជា តំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង

សូមអរគុណ !

៤

ការវិភាគ SWOT របស់មន្ទីរ សហវ. ខេត្តបន្ទាយមានជ័យ

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

បទបង្ហាញស្តីពី

ទិដ្ឋភាពសង្គម សេដ្ឋកិច្ច និងការវិភាគ SWOT
ដើម្បីកំណត់ពីសក្តានុពល និងបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍

មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្តបន្ទាយមានជ័យ

ថ្ងៃអង្គារ ៤កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០២១

មាតិកា

១. ទិដ្ឋភាពសង្គម សេដ្ឋកិច្ច

ក. ពត៌មានទូទៅ (ទីតាំងភូមិសាស្ត្រនិងអាកាសធាតុ ប្រជាសាស្ត្រ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន)

ខ. វិស័យកសិកម្ម

គ. កម្មន្តសាល និង សកម្មភាពក្នុងវិស័យសេវាកម្ម

ឃ. វិស័យទេសចរណ៍

ង. វិស័យហិរញ្ញវត្ថុ

២. ការវិភាគ SWOT ដើម្បីកំណត់ពីសក្តានុពល និងបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍

ក. ភាពខ្លាំង

ខ. ភាពខ្សោយ

គ. ឱកាស

ឃ. ការគំរាមកំហែង

៣. សេចក្តីសន្និដ្ឋាន

១ ទិដ្ឋភាពសង្គម សេដ្ឋកិច្ច



១. ទិដ្ឋភាពសង្គម សេដ្ឋកិច្ច

ក ព័ត៌មានទូទៅ

ទីតាំងភូមិសាស្ត្រ និងអាកាសធាតុ:

❖ខេត្តបន្ទាយមានជ័យ ស្ថិតនៅទិសពាយ័ព្យនៃប្រទេសកម្ពុជា មានចម្ងាយ៣៥៩គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ តាមបណ្តោយផ្លូវជាតិលេខ ៥ មានព្រំប្រទល់ខាងជើងជាប់នឹងខេត្តឧត្តរមានជ័យ និងខេត្តស្រះកែវ ប្រទេសថៃ ខាងត្បូងជាប់នឹងខេត្តបាត់ដំបង ខាងកើតជាប់នឹងខេត្តសៀមរាប ខាងលិចជាប់នឹងប្រទេសថៃ និងមានខ្សែបន្ទាត់ព្រំដែនជាប់ប្រទេសថៃប្រវែង ១៥៣គម ដែលលាតសន្ធឹងពីភូមិសាស្ត្ររបស់ស្រុកម៉ាឡៃ ក្រុងប៉ោយប៉ែត ស្រុកអូរជ្រៅ ស្រុកស្វាយចេក រហូតដល់ស្រុកថ្មពួក។

❖ខេត្តមានផ្ទៃដីសរុប ៦ ៦៧៩ គីឡូម៉ែត្រការេ។ ទីប្រជុំជនរបស់ខេត្ត គឺក្រុងសិរីសោភ័ណ។

១. ទិដ្ឋភាពសង្គម សេដ្ឋកិច្ច

ទីតាំងភូមិសាស្ត្រ និងអាកាសធាតុ:

❖ខេត្តមានរដ្ឋបាលក្រុង ស្រុកចំនួន៩

- ❑ មានក្រុងចំនួន២៖ ក្រុងសិរីសោភ័ណនិង ក្រុងប៉ោយប៉ែត
- ❑ មានស្រុកចំនួន៧៖ ស្រុកមង្គលបូរី ស្រុកភ្នំស្រុក ស្រុកព្រះនេត្រព្រះ ស្រុកអូរជ្រៅ ស្រុកថ្មពួក ស្រុកស្វាយចេក ស្រុកម៉ាឡៃ

❖ ចែកចេញជា ១០ សង្កាត់ និង ៥៥ឃុំ ស្មើនឹង ៦៥៨ភូមិ។

❖យោងតាមការព្យាករណ៍ អាកាសធាតុ នៅឆ្នាំ ២០១៩ សីតុណ្ហភាពអតិបរមា ៣១.២ អង្សារសេ និងសីតុណ្ហភាព អប្បរមា ២៣.១ អង្សារសេ។ ទិន្នន័យទឹកភ្លៀងប្រចាំឆ្នាំ ២០១៩ មានចំនួន ៩៥៧.២មម។

១. ទិដ្ឋភាពសង្គម សេដ្ឋកិច្ច

ប្រជាសាស្ត្រ (CDB 2020)

លេខរៀង	បរិយាយ	២០១៨	២០១៩	២០២០
១	ចំនួនប្រជាជនសរុប (នាក់)	៧៨៩ ៩៥៣	៨១១ ០៣៧	៨១៥ ៥២២
២	អត្រាកំណើនប្រចាំឆ្នាំ (%)	១.៥៨	២.៦៧	០.៥៥
៣	សរុបប្រុស	៣៩៦ ២៩២	៤០៧ ២៥៤	៤០៩ ០៤១
៤	សរុបស្រី	៣៩៣ ៦៦១	៤០៣ ៧៨៣	៤០៦ ៤៨១
៥	ចំនួនគ្រួសារ	១៨៨ ៤៥៥	១៩២ ៦១០	១៩៤ ៨៦៣
៦	ចំនួនមនុស្សអាយុ ០-១៧ឆ្នាំ	២៧៥ ៣៩៥	២៨៣ ១០៥	២៨៥ ៨៤១
៧	%មនុស្សអាយុ ០-១៧ឆ្នាំ	៣៤.៨៦	៣៤.៩១	៣៥.០៥
៨	ចំនួនមនុស្សអាយុ ១៨-៦០ឆ្នាំ	៤៥០ ៣៨៧	៤៦៣.១៩៣	៤៦២ ១៣០
៩	%មនុស្សអាយុ ១៨-៦០ឆ្នាំ	៥៧.០១	៥៧.១១	៥៦.៦៧
១០	ចំនួនមនុស្ស អាយុ ៦១ ឆ្នាំ ឡើង	៦៤ ១៧១	៦៤ ៧៣៩	៦៧ ៥៥១
១១	%មនុស្សអាយុ អាយុ៦១ឆ្នាំឡើង	៨.១២	៧.៩៨	៨.២៨

១. ទិដ្ឋភាពសង្គម សេដ្ឋកិច្ច



១. ទិដ្ឋភាពសង្គម សេដ្ឋកិច្ច

ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

❖ទិន្នន័យផ្លូវជាតិ ផ្លូវខេត្ត ផ្លូវក្រុង និង ផ្លូវក្រវ៉ាត់ក្រុង បច្ចុប្បន្នមានប្រវែងសរុប ៦៥៤.៨៣ គ.ម ក្នុងនោះផ្លូវចាក់កៅស៊ូ និង បេតុង បានប្រវែង ៤៦៣.៦៧ គ.ម ស្មើនឹង ៧១% នៃប្រវែងសរុបទូទាំងខេត្ត ។

❖ផ្លូវជាតិលេខ៦ ខ្ទង់ និង ផ្លូវជាតិលេខ៦៧ខ្ទង់ មាន៦ ខ្សែ ប្រវែង ៣៥៤.៦៨ គម ។

❖ផ្លូវខេត្តលេខ៣ខ្ទង់ និង លេខ៤ខ្ទង់ មាន១១ខ្សែ ប្រវែងសរុប ២៤៨៥៥ គម និង ផ្លូវមួយចំនួនទៀតកំពុងសាងសង់ដោយកងវិស្វកម្មតេជោហ៊ុនសែនសៀមរាប និងក្រសួងស្ថាប័នមួយចំនួនទៀត។

រូបភាពបង្ហាញប្រវែងផ្លូវបែងចែកតាមប្រភេទឆ្នាំ ២០១៩



១. ទិដ្ឋភាពសង្គម សេដ្ឋកិច្ច

ខ. វិស័យកសិកម្ម

❖ខេត្តមានផ្ទៃដី បង្កបង្កើនផលសរុប៣៦៣ ៦៥៧ ហិកតា ស្មើនឹង ៥៤.៤%នៃផ្ទៃដីសរុប ។ (ផែនការអភិវឌ្ឍន៍ខេត្តរយៈពេល៥ឆ្នាំ ២០២០-២០២៤ រដ្ឋបាលខេត្តបន្ទាយមានជ័យ)

❖យោងតាម CDB ឆ្នាំ ២០១៩ អត្រា ៦៨.២០% នៃចំនួនប្រជាជនដែលពេញកម្លាំងពលកម្ម (អាយុ ១៨-៦០ ឆ្នាំ) គឺជាអ្នកប្រកបរបរ កសិកម្មជាចម្បង។

បរិយាយ		២០១៨(%)	២០១៩(%)	២០២០	
				%	ចំនួនមនុស្ស
មនុស្សប្រកបរបរធ្វើកសិកម្ម		៦៩.៣	៦៨.២	៦៦.៩	២២១ ៥៥៧
ក្នុងនោះ	ធ្វើស្រែ	៥៧.៥៥	៥៨.៣៥	៥៦.៣៧	១៨៦ ៥៥៧
	ដាំដំណាំរយៈពេលវែង	៣.០០	២.៣៩	២.៦៨	៨ ៨៧៦
	ដាំដំណាំរយៈពេលខ្លី	៥.១៣	៤.០៨	៣.៨៣	១២ ៦៨២
	ដាំដំណាំបន្លែ	១.៦២	១.៣១	១.៥៤	៥ ០៩៧
	នេសាទ	០.៣០	០.២៦	០.៣៣	១ ០៨៦
	ចិញ្ចឹមសត្វ	១.៦៧	១.៧៣	២.១៤	៧ ០៨២
	អនុផលព្រៃឈើ	០.០៥	០.០៥	០.០៥	១៧៧

១. ទិដ្ឋភាពសង្គម-សេដ្ឋកិច្ច

ខ.វិស័យកសិកម្ម (ផលិតកម្មស្រូវ)

បរិយាយ	២០១៨	២០១៩	២០២០
សរុបផ្ទៃដីបានធ្វើស្រែ	៣៣៥ ១៣៤.១	៣៤៥ ២១៧.៩	៣២៣ ៧៤៤.៥
សរុបបរិមាណផលស្រូវ(តោន)	៨៤០ ៣៦១.៤	៨១៧ ៥៨៩.១	៥៩៦ ២៨៤.៨
ទិន្នផលស្រូវជាមធ្យម (ត/ហ.ត)	២.៥	២.៤	១.៨
ចំណូលជាមធ្យម ក្នុងប្រជាជនម្នាក់ ពីដំណាំស្រូវ (ដុល្លារ)	២២៣.៥	២០១.៦	១៤១.០

(ប្រភព CDB 2020)

១. ទិដ្ឋភាពសង្គម សេដ្ឋកិច្ច

ខ. វិស័យកសិកម្ម

ទិន្នផលស្រូវជាមធ្យម (CDB2020)



១. ទិដ្ឋភាពសង្គម សេដ្ឋកិច្ច

ខ.វិស័យកសិកម្ម

បរិមាណផលស្រូវ ផលិតបានក្នុងមួយឆ្នាំ(CDB 2020)



១. ទិដ្ឋភាពសង្គម សេដ្ឋកិច្ច

ខ.វិស័យកសិកម្ម

ទិន្នផលស្រូវប្រាំង និង វស្សា ជាមធ្យម (ប៉ាន់ស្មាន CDB 2020)



១. ទិដ្ឋភាពសង្គម សេដ្ឋកិច្ច

ខ. វិស័យកសិកម្ម (ដំណាំរយៈពេលខ្លី)

ប្រភេទដំណាំ	បរិមាណផល (តោន)		២០២០		
	២០១៨	២០១៩	បរិមាណផល (តោន)	ទិន្នផលជាមធ្យម (ត/ហ)	ផ្ទៃដីបានដាំ (ហ.ត)
ពោត	១៤ ២៧០ .០៩	៣៩ ០៥៣.៣៩	២៨ ៩៨០.៦០	៤.៤០	៦ ៥៨៧
សណ្ដែកសៀង	៤៦០.០០	៣៦៤.៥៥	៨៣.២០	២.១៣	៣៩
សណ្ដែកបាយ	៩០៦.៣៣	៤២២.៨១	៥៦៣.៨៧	១.១០	៥១២
សណ្ដែកដី	១ ៣២០.០៨	៧.៨៨	៤.១៧	០.៨៣	៥
ដំឡូងមី	១ ១៥៦ ៨៧២.៤៩	៨៦៧ ១១១.១៤	៧៦៤ ០២៩.៤១	១១.១៩	៦៨ ២៥៥
ដំឡូងជ្វា	២៥៨.៣៣	៧២៦.៧៥	៦៧៤.៦៧	៧.៦៧	៨៨
ល្ហុរ	៤៦.៨០	៩៣.៦២	៦៧៨.៣៨	០.៩៩	៦៨៦

១. ទិដ្ឋភាពសង្គម សេដ្ឋកិច្ច

ខ. វិស័យកសិកម្ម (ដំណាំរយៈពេលវែង)

ប្រភេទដំណាំ	បរិមាណផល(តោន)		២០២០			
	២០១៨	២០១៩	បរិមាណផល (តោន)	ទិន្នផលជាមធ្យម (ត/ហ)	ផ្ទៃដីប្រមូលផល (ហ/ត)	ផ្ទៃដីបានដាំ (ហ/ត)
អំពៅ	១ ៤១៧.៣៣	១ ០០០.៣៥	៣៤៧.៧០	៩.១៥	៣៨	
កៅស៊ូ	១.៣២	៤៦.០០	៦.០០	០.១៥	៤០	១ ៤០២
ដូងប្រេង	២៦.២៥	០.៥៦	២៤.៥០	០.៧០	៣៥	៥០
ម្រេច	២.៥០	២.០៣	៤.៨០	១.២០	៤	៤
ស្វាយចន្ទី	១ ២១៥.៧៣	៣ ៩៤០.១៣	៣ ១៤១.៦០	២.១០	១ ៤៩៦	៩ ៦៨៨
ស្វាយ	៣ ១៦៤.៦៧	៦ ៦២៣.២០	៧ ៣៧៦.១៥	៨.៧៣	៨៤៥	២ ១៦៣
ធុរេន					០	១
មៀនប៉ៃលិន	២ ៣២៣.០០	២៧ ៤៩៣.២០	៥៣២.០០	២.០០	២៦៦	៦៥២
ក្រូចពោធិសាត់	៧៦.២៥	៤០.៦៩	១៤.០០	១.៧៥	៨	១០

១. ទិដ្ឋភាពសង្គម សេដ្ឋកិច្ច

ខ. វិស័យកសិកម្ម (ការចិញ្ចឹមសត្វ)

ប្រភេទសត្វចិញ្ចឹម	តម្លៃមធ្យម (ដុល្លារ)	តម្លៃសរុប (ដុល្លារ)		២០២០		
		២០១៨	២០១៩	តម្លៃសរុប	សរុបសត្វដែលចិញ្ចឹម	%គ្រួសារចិញ្ចឹមសត្វ
គោ	២០០	១៣ ០៨១ ០០០	១៤ ១៣៣ ៨០០	១៤ ១២៣ ៨០០	៧០ ៦១៩	៧.៨៥
ក្របី	២០០	៨៦៧ ០០០	១ ២៩៦ ៤០០	១ ១២៩ ៨០០	៥ ៦៤៩	០.៤០
ជ្រូក	៥០	១ ៩៨៨ ៥០០	១ ៤៩៥ ០៥០	១ ៥១៨ ១០០	៣០ ៣៦២	៣.៧៩
មាន់	៤	២ ៣៤៩ ៨៧៦	២ ៤១៦ ៨១៦	២ ៦៨៤ ៧៤៨	៦៧១ ១៨៧	៥០.៥៥
ទា	៣	១ ១៧៨ ២៣២	១ ១៣២ ៥២៤	១ ០៧៥ ៨១២	៣៥៨ ៦០៤	៥.៤៥
ពពែ	៥០	៤៣ ៣៥០	៣៣ ៦០០	៧០ ១៥០	១ ៤០៣	០.០៣
ក្រពើ	១០	៣៩ ៥០០	៤១ ៤៤០	៣៥ ៥៤០	៣ ៥៥៤	០.០១
ត្រី	២.៥	១៦២ ០៤៨	១២៥ ៧៩០	៣១៧ ០៣០	១២៦ ៨១២	០.១១
បង្កង	៧	៣៥០	១៦ ១០០	៥៣៧ ២៨៥	៧៦ ៧៥៥	០.០១
បង្គារ	៥	០	៥ ០០០	៨ ៦២០	១ ១៧២៤	០.០១
តម្លៃសរុប		១៩ ៧០៩ ៨៥៦	២០ ៦៩៦ ៥២០	២១ ៥០០ ៨៨៥		

១. ទិដ្ឋភាពសង្គម សេដ្ឋកិច្ច

ខ. វិស័យកសិកម្ម (ដីស្រែ មានប្រព័ន្ធស្រោចស្រព)

បរិយាយ		២០១៨	២០១៩	២០២០
សរុបដីស្រែទទួលបានពីប្រព័ន្ធស្រោចស្រព(ហ.ត)		៦៥ ៤០៥	៦៣ ២៤៩	៥៦ ១៦៩
ក្នុងនោះ	ដីស្រែវស្សា ទទួលបានពីប្រព័ន្ធស្រោចស្រព	៣៦ ៤៩១	៣៤ ២៥៥	២៨ ៩៤៧
	ដីស្រែប្រាំង ទទួលបានពីប្រព័ន្ធស្រោចស្រព	២៨ ៩១៤	២៨ ៩៩៤	២៧ ២២២
%ដីស្រែ ទទួលបានពីប្រព័ន្ធស្រោចស្រព		១៩.៨	២០.២	១៧.៩
ចំនួនគ្រួសារមានដីស្រែទទួលទឹកពីប្រព័ន្ធធារាសាស្ត្រ		១៦ ៧៤១	១៦ ៧៥៣	១៥ ៩៩៥
%គ្រួសារមានដីស្រែទទួលទឹកពីប្រព័ន្ធធារាសាស្ត្រ		៨.៩	៨.៧	៨.២

១. ទិដ្ឋភាពសង្គម សេដ្ឋកិច្ច

ខ. វិស័យកសិកម្ម (ដីស្រែ មានប្រព័ន្ធស្រោចស្រព)

ភាគរយផ្ទៃដីធ្វើស្រែមានប្រព័ន្ធស្រោចស្រព



១. ទិដ្ឋភាពសង្គម សេដ្ឋកិច្ច

គ. កម្មន្តសាល និង សកម្មភាពក្នុងវិស័យសេវាកម្ម

បរិយាយ		២០១៨	២០១៩	២០២០
%អ្នកមានមុខរបរ ក្នុងវិស័យកសិកម្ម		៦៩.៣	៦៨.២	៦៦.៩
សរុបអ្នកមានមុខរបរចំបងក្រៅវិស័យកសិកម្ម		៩៩ ៣០៣	១០៦ ៤២៥	១០៩ ៣៩៨
ក្នុងនោះ	អ្នកមានមុខរបរចំបងផ្នែក ផលិតកម្ម	២ ២០៩	២ ៨៦១	២ ៤០៦
	អ្នកមានមុខរបរចំបងផ្នែក សេវាកម្ម	៩៧ ០៩៤	១០៣ ៥៦៤	១០៦ ៩៩២
%អ្នកមានមុខរបរ ចំបងក្រៅវិស័យកសិកម្ម		៣០.៧	៣១.៨	៣៣.១

១. ទិដ្ឋភាពសង្គម សេដ្ឋកិច្ច

គ. កម្មន្តសាល និង សកម្មភាពក្នុងវិស័យសេវាកម្ម

ភាគរយអ្នកមានមុខរបរ ចំបងក្រៅវិស័យកសិកម្ម



១. ទិដ្ឋភាពសង្គម សេដ្ឋកិច្ច

គ. កម្មន្តសាល និង សកម្មភាពក្នុងវិស័យសេវាកម្ម

ទីតាំងផលិតកម្ម និងសេវាកម្ម

បរិយាយ	២០១៨	២០១៩	២០២០
សរុបទីតាំងផលិតកម្ម និង សេវាកម្ម	៩ ៧៤៤	១០ ៦១២	១០ ៨៣២
សរុបអ្នកធ្វើការងារតាមទីតាំង ផលិតកម្ម និង សេវាកម្ម	២១ ០៤០	២២ ៩៧៧	២៣ ៥០០

១. ទិដ្ឋភាពសង្គម សេដ្ឋកិច្ច

គ. កម្មន្តសាល និង សកម្មភាពក្នុងវិស័យសេវាកម្ម (ទីតាំងផលិតកម្ម)

បរិយាយ	២០១៨	២០១៩	២០២០		
	ចំនួនទីតាំង	ចំនួនទីតាំង	ចំនួនទីតាំង	ចំនួនមនុស្សបំរើការងារ	
				សរុប	ស្រី
ម៉ាស៊ីនកិនស្រូវខ្នាតមធ្យមឬធំ	៥៦៧	៧៦៤	៦៣៦	១៦០៨	៦៦០
ការធ្វើអជីវកម្មផ្តល់ថាមពល	៣១	២៥	៣៧	២៤២	៧៤
សិប្បកម្មឡតដ្ឋ	១៨	១៥	២៥	១១៣	៣៩
សិប្បកម្មផលិតអំបិល	៥	១	៩	១៣	៧
សិប្បកម្មត្បាញរវៃ	៣៤	៤៨	៤៩	១១៦	១០២
សិប្បកម្មផលិតពីផ្តៅ ឫស្សី ល្ពាក់	១០០	៤២	១១៦	២៨៩	៨៤
សិប្បកម្មផលិតគ្រឿងសង្ហារឹមពីឈើ	១១៣	១២៤	១២៩	៣១៤	៦៦
សិប្បកម្មចម្លាក់ពីស្ពាន់ ថ្ម ស្បែក	១៤	៩	២០	៧៥	១៦
សិប្បកម្មផលិតពីដែក អាលុញមីញ៉ូម..	៣៨	៣៨	៥៦	១៦៥	៣១
សិប្បកម្មផលិតពីជ័រ	៧	៤	១២	៦៨	២៣
សិប្បកម្មផលិតទឹកសុទ្ធ	៩៣	១៣៣	១៥៥	៥៨៦	២៥១
សិប្បកម្មកែឆ្នៃឬវិចខ្ចប់គ្រាប់ធញ្ញជាតិ	៥០	៩០	៨៧	២១០	១១៨
សិប្បកម្មកែឆ្នៃឬវិចខ្ចប់ផលនេសាទ	២៣	៣២	៣៨	១២៤	៦៩
សិប្បកម្មផ្សេងៗ	៧៣	៨៤	៨២	២៤១	១៦៤

១. ទិដ្ឋភាពសង្គម សេដ្ឋកិច្ច

គ. កម្មន្តសាល និង សកម្មភាពក្នុងវិស័យសេវាកម្ម (ទីតាំងសេវាកម្ម)

បរិយាយ	២០១៨	២០១៩	២០២០		
	ចំនួនទីតាំង	ចំនួនទីតាំង	ចំនួនទីតាំង	ចំនួនមនុស្សបំរើការងារ	
				សរុប	ស្រី
លក់គ្រឿងបរិភោគនិងទំនិញប្រើប្រាស់	៣,៤៥៣	៣,៥៦៩	៣,៤៥២	៧,២៦១	៤,៣៦២
លក់ខោអាវស្បែកជើង គ្រឿងក្រអូប	១,១១១	១,១៩៦	១,១៥៩	១,៧៦៥	១,២២៥
លក់គ្រឿងអលង្ការ	២៤២	២៣៨	២៤៨	៤៩៣	២៤១
លក់គ្រឿងអេឡិចត្រូនិក	១៩២	២០៧	២២៥	៤៤៥	១៧៨
លក់គ្រឿងសង្ហារឹម(តុ ទូ កៅអី)	៨១	៦៨	៧៤	២៣៥	៨៩
លក់សំភារៈសំណង់	២៧៦	២៩៦	៣៥០	១,០៣០	៤២៦
លក់សំភារៈសិក្សានិងកីឡា	១០៦	១០២	១១៦	២៨៦	១៦១
សេវាកម្មខ្នាតតូច(កាត់សក់ ម៉ាស្សារ..)	៤៨៦	៥៦០	៥៥២	៨៤៩	៤៩៤

១. ទិដ្ឋភាពសង្គម សេដ្ឋកិច្ច

គ. កម្មន្តសាល និង សកម្មភាពក្នុងវិស័យសេវាកម្ម (ទីតាំងសេវាកម្ម)

បរិយាយ	២០១៨	២០១៩	២០២០		
